F53/7

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 28 / 11 / 2019
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី
**Civil Party Lead Co-Lawyers' Section**
**Section des co-avocats principaux pour les parties civiles**

គោរពជូន
**លោក ស៊ា ម៉ៅ និងលោក ផន ធឿន**
**ក្រឡាបញ្ជីអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

កម្មវត្ថុ៖ **សេចក្តីប្រកាសអំពីលទ្ធភាពនៃទំនាស់ផលប្រយោជន៍**

ដូចលោកជ្រាបហើយ ខ្ញុំបានចូលកាន់តំណែងជាសហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹង រដ្ឋប្បវេណី នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩។ នៅពេលនេះ ខ្ញុំសូមប្រកាសអំពីលទ្ធភាពនៃទំនាស់ផលប្រយោជន៍ ដែលអាចដោះស្រាយបានយ៉ាងសមស្រប ប្រសិនបើវាជាបញ្ហាសំខាន់ដែលគួរឲ្យព្រួយបារម្ភ នោះ។

បញ្ហានេះ ទាក់ទិនទៅនឹងគម្រោងមួយនៅទីម័រខាងកើតដែលខ្ញុំបានចូលរួមជាមួយចៅក្រមបម្រុង Phillip Rapoza។ គម្រោងនេះគឺជាកិច្ចសហការរវាងអង្គការមូលនិធិអាស៊ី (The Asia Foundation) និងកម្មវិធីត្រួតពិនិត្យមើលប្រព័ន្ធតុលាការ (JSMP) ដែលជាអង្គការក្រៅរដ្ឋាភិបាលមួយនៅទីម័រខាងកើត ក្នុងគោលបំណងដើម្បីផលិតនូវសៀវភៅសិក្សាមួយស្តីអំពីច្បាប់ព្រហ្មទណ្ឌជាតិទីម័រ។ ខ្ញុំបានចុះកិច្ចសន្យាការងារជាមួយ JSMP ក្នុងតួនាទីជាអ្នកនិពន្ធនាំមុខ។ ចៅក្រម Rapoza បានយល់ព្រមជួយដល់អង្គការមូលនិធិអាស៊ី ដោយផ្តល់នូវធាតុចូលផ្នែកបច្ចេកទេសទៅលើសេចក្តីព្រាងនានា និងដឹកនាំកិច្ចពិគ្រោះយោបល់ជាមួយមន្ត្រីតុលាការជាន់ខ្ពស់នានានៅទីម័រ ដែលគាត់មានទំនាក់ទំនងតាំងពីយូរយារណាស់មកហើយ។ ខ្ញុំបានចូលរួមក្នុងគម្រោងនេះ តាំងពីចុងឆ្នាំ២០១៧ នៅពេលដែលខ្ញុំចាប់ផ្តើមផ្តល់ប្រឹក្សាយោបល់ *ដោយមិនយកប្រាក់កម្រៃ*អំពីសំណើរៀបចំគម្រោងនេះ។ ការងារគម្រោងនេះបានចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំ២០១៨ បើគិតទៅគម្រោងនេះដំណើរការបានពាក់កណ្តាលផ្លូវហើយ ដោយខ្ញុំបានបញ្ចប់សេចក្តីព្រាងទីមួយរបស់ខ្ញុំរួចហើយ។

ទំនាក់ទំនងការងារផ្ទាល់របស់ខ្ញុំជាមួយចៅក្រម Rapoza តិចតួចណាស់៖ កាលពីអតីតកាល ខ្ញុំធ្លាប់បានជួបគាត់រយៈពេលខ្លីចំនួនពីរលើក។ សម្រាប់ការងារគម្រោងនេះ យើងបានផ្ញើអ៊ីម៉ែលទៅវិញទៅមកមួយចំនួនតូច នៅក្នុងអំឡុងពេលនៃការរៀបចំសំណើគម្រោង និងនៅក្នុងដំណាក់កាលដំបូងនៃការងាររៀបចំសេចក្តីព្រាងរបស់ខ្ញុំ។ ចាប់តាំងពីខ្ញុំដាក់ពាក្យស្នើសុំតួនាទីជាសហមេធាវីនាំមុខអន្តរជាតិមក ខ្ញុំមិនដែលមានទំនាក់ទំនងផ្ទាល់ជាមួយចៅក្រម Rapoza ទេ។

ខ្ញុំយល់ថា ទំនាក់ទំនងបែបនេះរវាងចៅក្រម និងមេធាវី មិនមានអ្វីខុសប្រក្រតីនោះទេ ហើយមួយវិញទៀតសោត តួនាទីរបស់ចៅក្រម Rapoza គឺជាចៅក្រមបម្រុងប៉ុណ្ណោះ មិនមែនចៅក្រមពេញសិទ្ធិនោះឡើយ។ ហេតុនេះ ហានិភ័យនៃទំនាស់ផលប្រយោជន៍ ឬការយល់ឃើញអំពីទំនាស់ផលប្រយោជន៍នេះ មានកម្រិតទាបណាស់។ ទោះបីយ៉ាងណាក្តី ដើម្បីឲ្យមានតម្លាភាពពេញលេញនោះ ខ្ញុំយល់ថាគួរតែជម្រាបជូនអង្គជំនុំជម្រះតុលាការកំពូលអំពីបញ្ហានេះ។

ដោយសារតែវាជាបញ្ហាផ្ទាល់ខ្លួនរបស់ខ្ញុំ ខ្ញុំបានសម្រេចផ្ញើលិខិតនេះជូនលោកដោយមានចុះហត្ថលេខាតែរូបខ្ញុំប៉ុណ្ណោះ បន្ទាប់ពីបានពិភាក្សា និងមានការយល់ព្រមពីលោក ពេជ អង្គ ដែលជាសហមេធាវីនាំ

Original EN: 01627498-01627498